00981917

០០២/១៩-០៩-២០០៧-អវតក/អជសដ

**E305**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de réception): 09 / 04 / 2014
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ អូត្តារ**

កាលបរិច្ឆេទ: ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈ ដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**កត់សម្គាល់** នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ដែលអង្គជំនុំជម្រះបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងបានកំណត់នូវវិសាលភាពនៃសំណុំរឿង ០០២/០២[1]។

**រំឭកឡើងវិញ** នូវដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ អនុលោមទៅតាមបញ្ជីឈ្មោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលភាគីបានដាក់ ក្នុងចំណោមបញ្ជីសម្ភារៈនានា ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូល[2]។

**ហេតុដូច្នេះសម្រេច**

**បង្គាប់** ឱ្យភាគីដាក់សម្ភារៈនានាដូចខាងក្រោម សម្រាប់គោលបំណងនៃសំណុំរឿង ០០២/០២៖

I. <u>បញ្ជីឈ្មោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានធ្វើបច្ចុប្បន្នភាព ដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ ហើយដែលអ្នកទាំងនោះមិនបានស្នើសុំនូវវិធានការការពារ</u>

១. នៅឆ្នាំ ២០១១ ភាគីបានដាក់នូវបញ្ជីឈ្មោះ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលភាគីមិនបានស្នើសុំវិធានការការពារទេ។ អង្គជំនុំជម្រះស្នើសុំឱ្យភាគីដាក់បញ្ជីឯកសារទាំងនោះនៅក្នុងសំណៅឯកសារដែលបានធ្វើបច្ចុប្បន្នភាព សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។ ដីកាបង្គាប់នេះមិនអនុញ្ញាតឱ្យភាគីដាក់បន្ថែមឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ទៀតទេ។ ទោះជាយ៉ាងណាក្តី ពាក្យសុំណាមួយដើម្បីស្តាប់សក្ខីកម្មបុគ្គលបន្ថែម ត្រូវដាក់ដោយអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។

២. បញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពត្រូវដាក់ត្រឹមថ្ងៃ សុក្រ ទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ជាភាសាខ្មែរ និង ភាសាអង់គ្លេស ឬភាសាបារាំង។ អនុលោមតាមសេចក្តីណែនាំនានាពីមុន បញ្ជីឯក-

[1] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមសំណុំរឿង ០០២និងវិសាលភាពនៃសំណុំរឿង ០០២/០២, ឯកសារ E301/9/1, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤។

[2] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ឯកសារ E9, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ("ដីកាបង្គាប់ឱ្យដាក់សម្ភារៈ")។

សារទាំងនោះត្រូវមានព័ត៌មានទាក់ទងនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញនីមួយៗដែលភាគីបានស្នើសុំ ដូចខាងក្រោមនេះ ៖

១) គោត្តនាម និងនាម ភេទ ថ្ងៃ ខែ ឆ្នាំ កំណើត និងទីកន្លែងកំណើត។

២) អាសយដ្ឋានបច្ចុប្បន្ន និង/ឬ ព័ត៌មានពិស្តារសម្រាប់ទំនាក់ទំនង។

៣) រហស្សនាមនានាដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ពីមុន[3]។

៤) លេខយោងឯកសារដែលជាកំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត។

៥) វិធានការការពារដែលនៅជាធរមាន ព្រមទាំងឯកសារដែលជាសេចក្តីសម្រេចទាក់ទងនឹងវិធានការការពារទាំងនោះ។

៦) សេចក្តីអះអាងដែលបញ្ជាក់ពីទំនាក់ទំនងញាតិ ដូចមានចែងនៅក្នុងវិធាន ២៤(២)។

៧) ការប៉ាន់ស្មានន្ធូវរយៈពេលសម្រាប់ធ្វើសក្ខីកម្ម។

៨) ភាសាដែលប្រើប្រាស់សម្រាប់ធ្វើសក្ខីកម្ម ឬក្នុងពេលសវនាការ ។ និង

៩) ប្រភេទនៃសម្បថដែលត្រូវធ្វើ។

៣. បញ្ជីឈ្មោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានធ្វើបច្ចុប្បន្នភាព ត្រូវដាក់ជាឯកសារ "សម្ងាត់" រហូតដល់មានសេចក្តីសម្រេចជាចុងក្រោយពីអង្គជំនុំជម្រះសាលាដំបូងអំពីការធ្វើចំណាត់ថ្នាក់លើឯកសារទាំងនោះ[4]។ អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជូនបញ្ជីដែលបានធ្វើ

---

[3] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថានៅក្នុងបញ្ជីឈ្មោះ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលភាគីបានដាក់កាលពីពេលមុន - រហស្សនាម (*សូមមើល* ឧទាហរណ៍ ឯកសារ E9/35, E9/35/1 និង E935/1.1) ដែលអាចជួយដល់ភាគីក្នុងការរៀបចំសម្ភារៈដែលខ្លួនស្នើសុំ។

[4] អង្គជំនុំជម្រះសាលាដំបូងសូមរំឭកឡើងវិញថា តាមការអនុវត្ត របស់អង្គជំនុំជម្រះសាលាដំបូងដែលមានស្រាប់ និងអនុលោមទៅតាមការអនុវត្តនៅតុលាការអន្តរជាតិឯទៀតបុគ្គលដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងតុលាការត្រឹមតែរហស្សនាមប៉ុណ្ណោះ ព្រោះជាគោលការណ៍ដើម្បីការពារកុំឱ្យអ្នកសារព័ត៌មានយកអត្តសញ្ញាណអ្នកទាំងនោះទៅផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត។ បន្ទាប់ពីសាក្សីបានផ្តល់សក្ខីកម្មនៅក្នុងសវនាការជាសាធារណៈនោះ បុគ្គលទាំងនោះអាចនឹងត្រូវបានបង្ហាញអត្តសញ្ញាណ ក្នុងតុលាការដោយហៅឈ្មោះបាន (*សូមមើល* សេចក្តីសម្រេចទៅសំណើសុំឱ្យមានវិធានការការពារទាំងអស់ក្នុងសំណុំរឿង ០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅសាក្សី ស សារិន សាជាថ្មី និងដីកាបង្គាប់ឱ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ (E286), ឯកសារ E239, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣។

បច្ចុប្បន្នភាពទាំងនោះទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងរយៈពេលមួយសមស្រប និងតាមការចាំបាច់ដើម្បីត្រៀមរៀបចំសវនាការ។

៤. បញ្ជីដែលបានធ្វើបច្ចុប្បន្នភាពទាំងនេះត្រូវរៀបចំក្នុងទម្រង់ជាតារាងដូចទៅនឹងឯកសារគំរូដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងឯកសារ E9[5]។ ភាគីនីមួយៗត្រូវផ្តល់សំណៅឯកសារជាទម្រង់ Microsoft Word នូវបញ្ជីរបស់ខ្លួនដែលបានធ្វើបច្ចុប្បន្នភាពមកឱ្យក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង សម្រាប់ប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះ។

II. <u>បញ្ជីឈ្មោះ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ ដែលស្នើសុំវិធានការការពារ</u>

៥. ប្រសិនបើមាន សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញដែលភាគីមានបំណងកោះហៅ ហើយដែលអ្នកទាំងនោះ**មានបំណងស្នើសុំនូវវិធានការការពារ** បញ្ជីឈ្មោះអ្នកដែលស្នើសុំវិធានការការពារនេះត្រូវដាក់ដោយឡែកឱ្យបានត្រឹមថ្ងៃ សុក្រ ទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬភាសាបារាំង។ បញ្ជីទាំងនេះត្រូវរៀបចំក្នុងទម្រង់ជាតារាង និងត្រូវមានការចង្អុលបង្ហាញដោយសង្ខេបពីការស្នើសុំវិធានការការពារនោះ។ ក្នុងពេលរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះចំពោះសំណើសុំវិធានការការពារ និងស្ថានភាពនៃភាពសម្ងាត់នេះ បញ្ជីទាំងនេះនឹងត្រូវដាក់ជាឯកសារ "សម្ងាត់បំផុត"[6]។ ជាការអនុវត្ត បញ្ជីទាំងនេះក៏ត្រូវមានព័ត៌មានដូចមានរៀបរាប់ក្នុងកថាខណ្ឌ ២ ខាងលើផងដែរ[7]។

៦. អង្គជំនុំជម្រះសាលាដំបូងនឹងស្នើសុំឱ្យភាគីបង្ហាញអំពីមូលហេតុដែលនាំឱ្យពួកគេស្នើសុំវិធានការការពារពាក់ព័ន្ធនឹងបុគ្គលម្នាក់ៗ ទៅតាមពេលវេលាសមស្រប។ បន្ទាប់ពីសម្រេចលើសំណើសុំវិធានការការពារ អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱកាសឱ្យភាគីផ្តល់មតិយោបល់ទៅលើបញ្ជីទាំងនេះ។

III. <u>ព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពដែលតម្រូវឱ្យមាន ទាក់ទងទៅនឹង សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ នានា ដែលភាគីបានស្នើសុំ</u>

---

[5] ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱ្យភាគីនូវសំណៅជាទម្រង់ Microsoft Word នៃគំរូសម្រាប់តារាងទាំងនេះ។

[6] អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជូនបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពទាំងនេះទៅឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញទៅតាមពេលវេលាសមស្រប និងតាមការចាំបាច់សម្រាប់គោលបំណងនៃការរៀបចំសវនាការ។

[7] ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱ្យភាគីនូវសំណៅជាទម្រង់ Microsoft Word នៃគំរូសម្រាប់តារាងទាំងនេះ។

៧. នៅឆ្នាំ ២០១១ ភាគីបានផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលភាគីបានស្នើសុំ។ អង្គជំនុំជម្រះបង្គាប់ឱ្យភាគីដាក់សំណៅដែលបានធ្វើបច្ចុប្បន្នភាពនៃព័ត៌មានទាំងនេះសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ក្នុងទម្រង់ជាតារាង[8]។ តារាងទាំងនេះក៏ត្រូវដាក់ត្រឹមថ្ងៃ សុក្រ ទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬភាសាបារាំងដែរ។ អនុលោមតាមសេចក្តីណែនាំកន្លងទៅ អង្គជំនុំជម្រះបង្គាប់ថាព័ត៌មានទាំងនេះគួររួមមាន៖

១) សេចក្តីសង្ខេបនៃអង្គហេតុ ដែលសាក្សីនីមួយៗនឹងត្រូវធ្វើសក្ខីកម្ម ឬសេចក្តីសង្ខេបអង្គហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនឹងមកធ្វើសេចក្តីថ្លែងការណ៍ ឬផលប៉ះពាល់នៃបទល្មើសដែលត្រូវបានចោទប្រកាន់។ ដើម្បីអាចកំណត់បាននូវវិធានការការពារណាមួយនោះ សេចក្តីសង្ខេបនៃអង្គហេតុត្រូវមានព័ត៌មានលម្អិតគ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះ ឬភាគីអាចយល់បានពេញលេញនូវលក្ខណៈ និងខ្លឹមសារនៃការធ្វើសក្ខីកម្មដែលបានស្នើសុំនោះ។

២) សេចក្តីសង្ខេបអំពីភាពជំនាញ និងគុណវុឌ្ឍិរបស់អ្នកជំនាញដែលភាគីបានស្នើសុំ។ ដើម្បីអាចកំណត់បាននូវវិធានការការពារណាមួយនោះ សេចក្តីសង្ខេបនៃអង្គហេតុត្រូវមានព័ត៌មានលម្អិតគ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះ ឬភាគីអាចយល់បានពេញលេញនូវលក្ខណៈ និងខ្លឹមសារនៃការធ្វើសក្ខីកម្មរបស់អ្នកជំនាញដែលបានស្នើសុំនោះ។ និង

៣) ចំណុចនៃការចោទប្រកាន់ ដែលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ ដែលភាគីបានស្នើសុំនោះ រំពឹងថានឹងមកផ្តល់សក្ខីកម្ម ហើយត្រូវបញ្ជាក់ផងដែរនូវលេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ[9]។

ភាគីនីមួយៗ ត្រូវផ្តល់សំណៅជាទម្រង់ Microsoft Word នូវបញ្ជីរបស់ខ្លួនដែលបានធ្វើបច្ចុប្បន្នភាពទៅឱ្យក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង សម្រាប់ប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះ។

[8] ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱ្យភាគីនូវសំណៅជាទម្រង់ Microsoft Word នៃគំរូសម្រាប់តារាងទាំងនេះ។

[9] អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង០០២/០២ មានរៀបចំបញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ដែលអាចជួយដល់ភាគីក្នុងការរៀបចំសម្ភារៈដែលខ្លួនស្នើសុំដាក់។

IV. ការជំទាស់ទៅនឹងការកោះហៅ សាក្សី និងអ្នកជំនាញ ដែលភាគីបានស្នើសុំ

៨. អនុវត្តតាមចំណុច II ខាងលើ ហើយដោយមិនឱ្យហួសពីថ្ងៃ សុក្រ ទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ភាគីក៏ត្រូវចង្អុលបង្ហាញផងដែរ ថាតើភាគីនីមួយៗមានបំណងជំទាស់ទៅនឹងការកោះហៅសាក្សី ឬអ្នកជំនាញដែលភាគីបានស្នើសុំដែរឬទេ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការជំទាស់នោះ។ អង្គ-ជំនុំជម្រះសាលាដំបូងនឹងធ្វើការពិចារណា ថាតើខ្លួនមានបំណងស្នើឱ្យភាគីដែលជំទាស់នោះដាក់នូវសារណាបន្ថែមដែរ ឬយ៉ាងណា នៅពេលក្រោយ។

V. បញ្ជីអង្គហេតុដែលភាគីមិនមានការតវ៉ា

៩. សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី ត្រូវដាក់បញ្ជីរួមគ្នានូវអង្គហេតុដែលមិនមានការតវ៉ា អនុលោមតាមវិធាន ៨០(៣)(ង) មិនឱ្យហួសពីថ្ងៃ សុក្រ ទី ០៦ ខែ មិថុនា ឆ្នាំ ២០១៤។

១០. សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី ត្រូវបន្តសហការគ្នាជាប្រចាំ ហើយត្រូវរាយការណ៍ជូនអង្គជំនុំជម្រះឱ្យបានឆាប់រហ័សអំពីអង្គហេតុ ឬអង្គហេតុដែលបញ្ជាក់ដោយភស្តុតាងណាមួយ ដែលក្រោយមកខ្លួនបានទទួលស្គាល់ថាជាអង្គហេតុមិនមានការតវ៉ា។

VI. បញ្ជីឯកសារ និងវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព[10]

១១. ភាគីក៏ត្រូវផ្តល់សំណៅបញ្ជីឯកសារដែលបានដាក់ពីពេលមុន ហើយដែលបានធ្វើបច្ចុប្បន្នភាពរួចហើយនោះ មិនឱ្យហួសពីថ្ងៃ សុក្រ ទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤។ ឯកសារទាំងនេះត្រូវបង្ហាញនូវអត្តសញ្ញាណឱ្យបានសមស្រប[11] តាមរយៈលេខឯកសារយោងបច្ចុប្បន្នរបស់វា[12] ចំណងជើង ភាសាដែលមាន ហើយត្រូវពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា

[10] អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា មានតែសហមេធាវីនាំមុខប៉ុណ្ណោះដែលធ្លាប់បានដាក់បញ្ជីវត្ថុតាង។

[11] ដោយឡែក ក្នុងករណីមានសៀវភៅ ឬឯកសារផ្សេងៗទៀតដែលមានកម្រាស់ច្រើនទំព័រនោះ បើអាច ភាគីត្រូវយោងទៅលើអត្ថបទដកស្រង់ដែលត្រូវបានកំណត់ថាពាក់ព័ន្ធបានហើយ។ ការចង្អុលបង្ហាញបែបនេះនឹងជួយសម្រួលដល់ការវាយតម្លៃពីសេចក្តីត្រូវការចាំបាច់ក្នុងការបកប្រែភាសាក្នុងសំណុំរឿង ០០២/០២។

[12] អង្គជំនុំជម្រះបានចង្អុលបង្ហាញរួចហើយថា ឯកសារនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ គឺជាកម្មវត្ថុនៃលក្ខខណ្ឌតម្រូវរបស់វិធាន៨៧(៣)និងត្រូវប្រើជាមូលដ្ឋានសម្រាប់សំណុំរឿង០០២/០២។ *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការបញ្ជាក់បំភ្លឺទាក់ទងនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី", ឯកសារ E302/5, ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤, កថាខណ្ឌ ៨។ ទោះជាយ៉ាងណាក្តី តម្រូវឱ្យមានការចង្អុលបង្ហាញនៃឯកសារទាំងនោះនៅក្នុងបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់ជាឯកសារយោង។

ព្រមទាំងចំណុចនៃការចោទប្រកាន់រួមមាន លេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ។

១២. ភាគីក៏ត្រូវផ្តល់ផងដែរ មិនឱ្យហួសពី ថ្ងៃ សុក្រ ទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ នូវបញ្ជីវត្ថុតាងដែលបានធ្វើបច្ចុប្បន្នភាព ហើយដែលខ្លួនមានបំណងដាក់ក្នុងសំណុំរឿង ០០២/០២ រួមមានការពន្យល់ដោយសង្ខេបអំពីលក្ខណៈ និងខ្លឹមសាររបស់វា ព្រមទាំងលេខឯកសារយោង និងចំណុចនៃការចោទប្រកាន់ រួមមាន លេខកថាខណ្ឌនៃដីកាដំណោះស្រាយ និងបទចោទជាក់លាក់ណាមួយ។

១៣. សម្ភារៈឯកសារនេះត្រូវដាក់ជាឯកសារ “សម្ងាត់” រហូតដល់មានសេចក្តីសម្រេចជាចុងក្រោយពីអង្គជំនុំជម្រះសាលាដំបូងអំពីការធ្វើចំណាត់ថ្នាក់លើឯកសារទាំងនេះ និងត្រូវរៀបចំក្នុងទម្រង់ជាតារាង[13]។ ភាគីនីមួយៗត្រូវផ្តល់ជូននូវបញ្ជីសម្ភារៈទាំងនេះជាទម្រង់ Microsoft Word ដែលបានធ្វើបច្ចុប្បន្នភាពមកឱ្យក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង សម្រាប់ប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះ។

១៤. ការស្នើសុំដាក់ឯកសារថ្មី ឬឯកសារបន្ថែម និង វត្ថុតាងថ្មី ឬវត្ថុតាងបន្ថែម ដែលមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ត្រូវដាក់ដោយអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។

## VII. <u>ការបង្ហាញអំពីបញ្ហាអង្គច្បាប់ផ្សេងៗមុនពេលសវនាការបឋម</u>

១៥. ភាគីក៏ត្រូវបង្ហាញនូវបញ្ហាអង្គច្បាប់ផ្សេងៗដែលខ្លួនមានបំណងលើកឡើងនៅក្នុងសវនាការបឋម ដោយមិនឱ្យហួសពីថ្ងៃ ចន្ទ ទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤។

ភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE
E.C.C.C * C.E.T.C.

និល ណុន

[13] ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ឱ្យភាគីនូវសំណៅជាទម្រង់ Microsoft Word នៃគំរូសម្រាប់តារាងទាំងនេះ។